01626583 F49

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះតុលាការកំពូល**
Supreme Court Chamber
Chambre de la Cour suprême

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

Case File/Dossier N°. 002/19-09-2007-ECCC/SC

**នៅចំពោះមុខ៖**

**ចៅក្រម គង់ ស្រ៊ីម ប្រធាន**
**ចៅក្រម Chandra Nihal JAYASINGHE**
**ចៅក្រម សោម សិរីវឌ្ឍ**
**ចៅក្រម Florence Ndepele Mwachande MUMBA**
**ចៅក្រម ម៉ុង មុន្នីចរិយា**
**ចៅក្រម Maureen Harding CLARK**
**ចៅក្រម យ៉ា ណារិន**

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 23-Aug-2019, 11:34
CMS/CFO: Sann Rada

**កាលបរិច្ឆេទឯកសារ៖** **ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៩**
**ភាសាដើម៖** **ខ្មែរ/អង់គ្លេស**
**ចំណាត់ថ្នាក់ឯកសារ៖** **សាធារណៈ**

---

# សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រ សម្រាប់ដាក់សារណាបណ្តឹងសាទុក្ខ

---

**សហព្រះរាជអាជ្ញា**
ជា លាង
Brenda HOLLIS (បម្រុង)

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
ពេជ អង្គ

**ជនជាប់ចោទ**
ខៀវ សំផន

**សហមេធាវីជនជាប់ចោទ ខៀវ សំផន**
គង់ សំអុន
Anta GUISSÉ

**អង្គជំនុំជម្រះតុលាការកំពូល**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យដែលបានប្រព្រឹត្តក្នុងអំឡុង ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ ("អង្គជំនុំជម្រះតុលាការកំពូល" និង "អ.វ.ត.ក") បានទទួល "សំណើរបស់ ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់ដាក់សារណាបណ្តឹងសាទុក្ខ" ("សំណើរបស់ ខៀវ សំផន") ដាក់នៅថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៩[1]។ នៅថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១៩ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងសហព្រះរាជអាជ្ញា បានដាក់សារណាតបទៅនឹងសំណើរបស់ ខៀវ សំផន[2]។ ខៀវ សំផន បានដាក់ចម្លើយតបរបស់ខ្លួន នៅថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៩[3]។

## I. <u>**ប្រវត្តិនីតិវិធី**</u>

1. នៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ អង្គជំនុំជម្រះសាលាដំបូង បានប្រកាសសាលក្រមក្នុងសំណុំរឿង ០០២/០២ ដោយបានដាក់ពិរុទ្ធភាពលើ នួន ជា និង ខៀវ សំផន ("ជនជាប់ចោទ") ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ និងបទប្រល័យពូជសាសន៍ ហើយបានសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត[4]។ អង្គជំនុំជម្រះសាលាដំបូងបានផ្តល់សេចក្តីសង្ខេបនៃសំអាងហេតុរបស់ខ្លួន និងបានបញ្ជាក់ថា ការកំណត់ពេលវេលាសម្រាប់ការដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ នឹងត្រូវចាប់ផ្តើមបន្ទាប់ពីការជូនដំណឹងអំពីសាលក្រមដែលមានសម្អាងហេតុ

---

[1] សំណើរបស់ ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់ដាក់សារណាបណ្តឹងសាទុក្ខ ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៩ ឯកសារលេខ F45 ("សំណើរបស់ ខៀវ សំផន")។

[2] សារណាតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងសំណើរបស់ ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់សារណាបណ្តឹងសាទុក្ខ ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១៩ ឯកសារលេខ F45/1 ("សារណាតបរបស់សហមេធាវីនាំមុខ")។ សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់ដាក់សារណាបណ្តឹងសាទុក្ខ ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១៩ ឯកសារលេខ F45/2 ("សារណាតបរបស់សហព្រះរាជអាជ្ញា")។

[3] ការឆ្លើយតបរបស់មេធាវីការពារក្តី ខៀវ សំផន ទៅនឹងសារណាតបទៅនឹងសំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់ដាក់សារណាបណ្តឹងសាទុក្ខ ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៩ ឯកសារលេខ F45/3 ("ការឆ្លើយតបរបស់ ខៀវ សំផន")។

[4] *សូមមើល*ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ (ការប្រកាសសាលក្រមក្នុងសំណុំរឿង ០០២/០២) ទំព័រ ៣៨ (ជួរ ២៥) ដល់ ៤១(ជួរ ១០)។

ពេញលេញ[5]។ បន្ទាប់មក អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងអំពីសាលក្រមពេញលេញនេះ ជាភាសាខ្មែរ អង់គ្លេស និងបារាំង នៅថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៩[6]។

2. នៅថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ខៀវ សំផន បានដាក់"បណ្តឹងសាទុក្ខភ្លាមៗ"ប្រឆាំងនឹងការប្រកាសរបស់អង្គជំនុំជម្រះសាលាដំបូង ដោយបានស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលសម្រេចទុកជាមោឃៈសេចក្តីសង្ខេបដែលបានប្រកាសនៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ដោយសារកង្វះផ្នែកទម្រង់ និងសុំឱ្យប្រកាសមោឃភាពសាលក្រមពេញលេញនោះ[7]។ នៅថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៩ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា "បណ្តឹងសាទុក្ខភ្លាមៗនោះ" ពុំអាចទទួលយកបាន[8]។

3. នៅថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៩ ខៀវ សំផន និង នួន ជា បានដាក់សំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរៀងៗខ្លួនប្រឆាំងនឹងសាលក្រមពេញលេញ[9]។ ខៀវ សំផន បានស្នើសុំពេលវេលាចំនួន ៨ ខែ (រួមបញ្ចូលពេលវេលាមួយខែសម្រាប់ការបកប្រែជាភាសាខ្មែរ) ដើម្បីដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខចំនួន ១០០ ទំព័រ។ នួន ជា បានស្នើសុំពេលវេលាសរុបចំនួន ១៨០ ថ្ងៃ សម្រាប់ដាក់សេចក្តីជូនដំណឹងចំនួន ១០០ ទំព័រ ជាភាសាអង់គ្លេស។ នៅថ្ងៃទី ២៦ ខែ

---

[5] *សូមមើល*ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ (ការប្រកាសសាលក្រមក្នុងសំណុំរឿង ០០២/០២) ទំព័រ ២ (ជួរ ២៣) ដល់ ៣(ជួរ ២)។

[6] សាលក្រមអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០២/០២ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ឯកសារលេខ E465 ("សាលក្រមអង្គជំនុំជម្រះសាលាដំបូង")។ អង្គជំនុំជម្រះតុលាការកំពូលសម្រេចថា ដោយសារសាលក្រមនេះត្រូវបានដាក់នៅក្រៅម៉ោងសម្រាប់ដាក់ឯកសារផ្លូវការរបស់ អ.វ.ត.ក. ការជូនដំណឹងមានប្រសិទ្ធភាពគឺគិតចាប់ពីថ្ងៃធ្វើការងារបន្ទាប់ គឺនៅថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៩៖ សេចក្តីសម្រេចលើសំណើរបស់ នួន ជា និង ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រលើសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៩ ឯកសារលេខ F43 កថាខណ្ឌ ១២។

[7] បណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសាលក្រមដែលបានប្រកាសនៅថ្ងៃទី ១៦ ខែ វិច្ឆកា ឆ្នាំ ២០១៨ ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ឯកសារលេខ E463/1។

[8] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ប្រឆាំងនឹងសេចក្តីសង្ខេបសាលក្រមដែលបានប្រកាសនៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៩ ឯកសារលេខ E463/1/3។

[9] សំណើបន្ទាន់លើកទីមួយរបស់ នួន ជា សុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៩ ឯកសារលេខ F40/1.1។ សំណើរបស់មេធាវីការពារក្តី ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៩ ឯកសារលេខ F39/1.1។

មេសា ឆ្នាំ ២០១៩ អង្គជំនុំជម្រះតុលាការកំពូលបានផ្តល់ការបន្ថែមដូចៗគ្នាដល់ភាគី ចំនួនពីរខែ និងចំនួនអតិបរមា ៦០ ទំព័រ ជាភាសាបារាំង ឬអង់គ្លេស រួមជាមួយនឹងការបកប្រែជាភាសាខ្មែរ។

4. នៅថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១៩ ខៀវ សំផន និង នួន ជា បានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០២[10]។ នៅក្នុងនោះ ខៀវ សំផន បានលើកកំហុសអង្គហេតុ និង/ឬអង្គច្បាប់ចំនួន ១.៨២៤ ដែលបានចោទប្រកាន់ថា អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តឡើង និងរកឃើញសេចក្តីសម្រេចបន្ទាន់បង្ហំចំនួន ៣៥៥ របស់អង្គជំនុំជម្រះសាលាដំបូងដែលអាចធ្វើបណ្តឹងសាទុក្ខបាន។

5. នៅថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៩ នួន ជា បានដាក់សំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់ដាក់សារណាបណ្តឹងសាទុក្ខរបស់ខ្លួន[11] ដែលជាការឆ្លើយតបសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានដាក់សារណាតបនៅថ្ងៃទី ០១ និង ០២ ខែ សីហា ឆ្នាំ ២០១៩ រៀងៗខ្លួន[12]។ នៅថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៩ ខៀវ សំផន បានឆ្លើយតបទៅនឹងការលើកឡើងរបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធទៅនឹងរូបគាត់[13]។ សហព្រះរាជអាជ្ញាបានដាក់សំណើកែប្រែនៅថ្ងៃទី ១៩ ខែ

---

[10] សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (០០២/០២) ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១៩ ឯកសារលេខ E465/4/1 កថាខណ្ឌ ១៥ ("សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ ខៀវ សំផន")។ សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១៩ ឯកសារលេខ E465/3/1។

[11] សំណើទីមួយរបស់ នួន ជា សុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់ដាក់សារណាបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៩ ឯកសារលេខ F47។

[12] សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ នួន ជា សុំបន្ថែមពេលេវេលា និងចំនួនទំព័រសម្រាប់ដាក់សារណាបណ្តឹងសាទុក្ខ ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៩ ឯកសារលេខ F47/1 ("សារណាតបរបស់សហព្រះរាជអាជ្ញា")។ សារណាតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងសំណើទីមួយរបស់ នួន ជា សុំបន្ថែមពេលវេលា និងចំនួនទំព័រដើម្បីដាក់សារណាបណ្តឹងសាទុក្ខរបស់គាត់ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១៩ ឯកសារលេខ F47/2 ("សារណាតបរបស់សហមេធាវីនាំមុខ")។

[13] សារណាតបរបស់មេធាវីការពារក្តី ខៀវ សំផន ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធទៅនឹងសារណាបណ្តឹងសាទុក្ខ (ឯកសារលេខ F47/1 កថាខណ្ឌ ២៥ ដល់ ២៦ (ii)) ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៩ ឯកសារលេខ F47/3 ("សារណាតបរបស់ ខៀវ សំផន ទៅនឹងសហព្រះរាជអាជ្ញា")។

សីហា ឆ្នាំ ២០១៩[14]។ នៅថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១៩ ខៀវ សំផន បានដាក់សារណាតបទៅនឹងសំណើកែប្រែរបស់សហព្រះរាជអាជ្ញា[15]។

6. នួន ជា បានទទួលមរណភាពនៅថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១៩[16]។ អង្គជំនុំជម្រះតុលាការកំពូលបានចេញសេចក្តីសម្រេចបញ្ចប់កិច្ចដំណើរការនីតិវិធីលើរូបគាត់នៅថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៩[17]។

## II. ការពិភាក្សា

7. សំណើរបស់ ខៀវ សំផន បានលើកបញ្ហាមួយចំនួនដែលអង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវដោះស្រាយតាមលំដាប់លំដោយដូចខាងក្រោម។

### ការបន្ថែមពេលវេលា និងចំនួនទំព័រ

*សារណា*

8. ខៀវ សំផន បានស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលបន្ថែមពេលវេលាដល់រូបគាត់ចំនួន ៨,៥ ខែ ដើម្បីដាក់សារណាបណ្តឹងសាទុក្ខចំនួន ៩៥០ ទំព័រ តែមួយភាសាសិន ការបកប្រែជាភាសាខ្មែរនឹងដាក់តាមក្រោយ[18]។ គាត់បានលើកឡើងថា ការកំណត់ពេលវេលា និងចំនួនទំព័រដោយវិធានផ្ទៃក្នុង និងសេចក្តីណែនាំអនុវត្ត "ពុំមានលក្ខណៈគ្រប់គ្រាន់យ៉ាងខ្លាំង" ដោយសារវិធានទាំងនេះ ពុំបានអនុញ្ញាតឱ្យគាត់"លើកទឡ្ហីករណ៍ និងសំអាងផ្លូវច្បាប់ដើម្បីគាំទ្រមូលដ្ឋាននីមួយៗ[របស់គាត់]"[19]។ ខៀវ សំផន បានសុំឱ្យអង្គជំនុំជម្រះពិចារណាទៅលើការបន្ថែមពេលវេលា និងចំនួនទំព័រដែលបានផ្តល់ឱ្យនៅក្នុងសំណុំរឿង ០០២/០១ និងស្នើសុំថា ការបន្ថែមក្នុងពេលបច្ចុប្បន្ន គប្បីផ្តល់ដោយពិចារណាទៅលើទំហំ និងភាពស្មុគស្មាញនៃសាល

---

[14] សំណើរបស់សហព្រះរាជអាជ្ញាស្នើសុំកែប្រែទៅលើសំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់សារណាទៅនឹងបណ្តឹងសាទុក្ខ ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៩ ឯកសារលេខ F48។

[15] "[សារណាតប]របស់មេធាវីការពារក្តីលោក ខៀវ សំផន ទៅនឹងសំណើកែប្រែរបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធនឹង[សារណាតប]ទៅនឹងសារណាបណ្តឹងសាទុក្ខ" ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១៩ ឯកសារលេខ F48/1 ("សារណាតបទៅនឹងសំណើកែប្រែ")។

[16] លិខិតបញ្ជាក់មរណភាពរបស់ នួន ជា ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១៩ ឯកសារលេខ F46/1.1។

[17] សេចក្តីសម្រេចបញ្ចប់កិច្ចដំណើរការនីតិវិធីលើ នួន ជា ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៩ F46/3។

[18] សំណើរបស់ ខៀវ សំផន កថាខណ្ឌ ១៩។

[19] សំណើរបស់ ខៀវ សំផន កថាខណ្ឌ ១៣។

ក្រុមអង្គជំនុំជម្រះសាលាដំបូង[20]។ គាត់បានអះអាងថា ធនធានមានកម្រិតបានបង្ខំចិត្តគាត់ឱ្យកំណត់កំហុសលំៗនៅក្នុងសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ និងថា អាស្រ័យហេតុនេះ គាត់ត្រូវការពេលវេលា និងចំនួនទំព័របន្ថែម ដើម្បីពិនិត្យឱ្យបានគ្រប់ជ្រុងជ្រោយលើសំអាងផ្លូវច្បាប់ និងអង្គហេតុដែលគាំទ្រសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូង[21]។ គាត់បានអះអាងថា សំណើរបស់គាត់“មិនទាមទារអ្វីឱ្យលើស ឬឱ្យតិច”ជាង“ការកម្រិតអប្បបរមា” ដើម្បីធ្វើបណ្តឹងសាទុក្ខប្រកបដោយអត្ថន័យនៅក្នុងកាលៈទេសៈនេះឡើយ[22]។

9. នៅក្នុងសារណាតប សហព្រះរាជអាជ្ញា“បានទទួលស្គាល់ថា ការបន្ថែមពេលវេលា និងចំនួនទំព័រ ដើម្បីដាក់សារណាបណ្តឹងសាទុក្ខ មានភាពចាំបាច់ក្នុងករណីនេះ” ប៉ុន្តែ បានលើកឡើងថា ការបន្ថែមទាំងនេះដែលបានស្នើឡើងដោយ ខៀវ សំផន មានលក្ខណៈច្រើនហួសហេតុពេក[23] និងថា រយៈពេលប្រាំខែ និងចំនួន ៣០០ ទំព័រ សម្រាប់ក្រុមមេធាវីនីមួយៗ ក្នុងការដាក់សារណាបណ្តឹងសាទុក្ខតែមួយភាសា មានលក្ខណៈសមហេតុផល[24]។ សហព្រះរាជអាជ្ញាបានលើកឡើងថា សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ដែល“មិនពេញលក្ខណៈ”ពុំមែនជាមូលដ្ឋានត្រឹមត្រូវមួយសម្រាប់ស្នើសុំបន្ថែមពេលវេលា និងចំនួនទំព័រនោះទេ និងបានកត់សម្គាល់ថា ភាគីនៃកិច្ចដំណើរការនីតិវិធីរឿងក្តីព្រហ្មទណ្ឌជានិច្ចកាលត្រូវបានផ្តល់ពេលវេលាជាក់លាក់មួយសម្រាប់បំពេញកាតព្វកិច្ចរបស់ខ្លួន[25]។ សហព្រះរាជអាជ្ញាបានអះអាងថា សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ ខៀវ សំផន មានទទ្ទឹករណ៍ត្រួតគ្នាជាច្រើនដែលពុំចាំបាច់ឱ្យមានចំនួនទំព័រច្រើននោះឡើយ[26]។ ចុងក្រោយ សហព្រះរាជអាជ្ញាជំទាស់ទៅនឹងការអះអាងរបស់ ខៀវ សំផន ដែលថា សំណើរបស់គាត់ស្របជាមួយនឹងការអនុវត្តរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិនានា[27]។ ជាការឆ្លើយតប ខៀវ សំផន បានបញ្ជាក់សាជាថ្មីថា ការបន្ថែមដែលបានស្នើសុំនេះ មានលក្ខណៈសមហេតុផល និងត្រូវបានលើកឡើងដោយគិតពិចារណាទៅលើបញ្ហាពាក់ព័ន្ធ ហើយ ខៀវ សំផន បានយោងទៅលើយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះថា ការប្រៀបធៀបជាមួយនឹងការអនុវត្តរបស់តុលាការព្រហ្ម

[20] សំណើរបស់ ខៀវ សំផន កថាខណ្ឌ ១៤ ដល់ ១៧។

[21] សំណើរបស់ ខៀវ សំផន កថាខណ្ឌ ១៧ ដល់ ១៨។

[22] សំណើរបស់ ខៀវ សំផន កថាខណ្ឌ ២៨។

[23] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៦។

[24] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៧។

[25] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៩។

[26] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១០។

[27] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៥ ដល់ ១៦។

ទណ្ឌអន្តរជាតិ "មានការជាប់ពាក់ព័ន្ធតិចតួចទៅនឹងបណ្តឹងសាទុក្ខនៅចំពោះមុខ អ.វ.ត.ក. លើកលែងតែបង្ហាញថា ម្ចាស់បណ្តឹងសាទុក្ខ [...] ត្រូវមានពេលវេលា និងចំនួនទំព័របន្ថែម[28]។

10. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីពុំបានជំទាស់ទៅនឹងការបន្ថែមពេលវេលា និងចំនួនទំព័រសមហេតុផលណាមួយ ប៉ុន្តែបានទទូចថា "ការបន្ថែមពេលវេលានោះត្រូវពិចារណាដល់សិទ្ធិ និងអត្ថប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ជាពិសេស វ័យចាស់ជរា និងបញ្ហាសុខភាព"[29]។ សហមេធាវីនាំមុខគោរពតាមឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះស្តីពីការបន្ថែមចំនួនទំព័រ[30]។

***ច្បាប់ជាធរមាន***

11. វិធាន ១០៧(៤)[31] នៃវិធានផ្ទៃក្នុងចែងថា "សារណាបណ្តឹងសាទុក្ខត្រូវដាក់ក្នុងរយៈពេល ៦០ (ហុកសិប)ថ្ងៃ គិតចាប់ពីថ្ងៃដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ"។ វិធាន ១០៥(៣) នៃវិធានផ្ទៃក្នុងតម្រូវឱ្យសារណាបណ្តឹងសាទុក្ខ"បញ្ជាក់ពីទឡ្ហីករណ៍ និងឯកសារសំអាងផ្លូវច្បាប់ដែលគាំទ្រមូលដ្ឋាននីមួយៗ"។ មាត្រា ៥.២ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារចំពោះមុខ អ.វ.ត.ក. ("សេចក្តីណែនាំអនុវត្ត")[32] ចែងថា ឯកសារដែលដាក់នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល"មិនត្រូវលើសពី ៣០ ទំព័រជាភាសាអង់គ្លេស ឬបារាំង ឬ ៦០ ទំព័រជាភាសាខ្មែរ លើកលែងតែមានបញ្ញត្តិចែងផ្ទុយពីនេះនៅក្នុងវិធានផ្ទៃក្នុងនៃ អ.វ.ត.ក សេចក្តីណែនាំអនុវត្តនេះ ឬបទបញ្ជាចេញដោយ អ.វ.ត.ក"។

12. វិធាន ៣៩(២) នៃវិធានផ្ទៃក្នុង អនុញ្ញាតឱ្យចៅក្រមកំណត់ពេលវេលាសម្រាប់ដាក់សារណាជាលាយលក្ខណ៍អក្សរ និងឯកសារពាក់ព័ន្ធទៅនឹងបណ្តឹងសាទុក្ខ ដោយពិចារណាទៅលើកាលៈទេសៈនៃរឿងក្តី ជាពិសេស ក្នុងករណីដែលជនជាប់ចោទកំពុងស្ថិតក្នុងមន្ទីរឃុំឃាំង។ វិធាន ៣៩(៤) នៃវិធានផ្ទៃក្នុងចែងថា "តាមពាក្យសុំរបស់ភាគីពាក់ព័ន្ធ ឬតាមគំនិតផ្តួចផ្តើមរបស់ខ្លួន [...] អង្គជំនុំជម្រះ អាចពន្យារពេលវេលាកំណត់ដែលខ្លួនបានកំណត់"។ មាត្រា ៥.៤ នៃសេចក្តីណែនាំអនុវត្តបានអនុញ្ញាតឱ្យអង្គជំនុំជម្រះ "បន្ថែមចំនួនទំព័រក្នុងករណីពិសេស"តាមសំណើរបស់ភាគី។

---

[28] ចម្លើយតបរបស់ ខៀវ សំផន កថាខណ្ឌ ៧ ដល់ ១៤។

[29] សារណាតបរបស់សហមេធាវីនាំមុខ កថាខណ្ឌ ៨។

[30] សារណាតបរបស់សហមេធាវីនាំមុខ កថាខណ្ឌ ៩។

[31] *សូមមើល* វិធានផ្ទៃក្នុងរបស់ អ.វ.ត.ក. វិសោធនកម្មលើកទី ៩ ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៥ (បានធ្វើវិសោធនកម្ម) ("វិធានផ្ទៃក្នុង")។

[32] *សូមមើល* សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក. វិសោធនកម្មលើកទី ៨។

13. ចុងក្រោយ មាត្រា ៧.១ នៃសេចក្ដីណែនាំអនុវត្តតម្រូវឱ្យរាល់ឯកសារត្រូវដាក់ជាភាសាខ្មែរ ព្រមទាំងភាសាអង់គ្លេស ឬបារាំង។

***ការពិចារណា***

14. ខៀវ សំផន បានស្នើសុំបន្ថែមរយៈពេល ៨,៥ ខែ និង ៩២០ ទំព័រទៅលើការផ្ដល់ឱ្យដែលបានកំណត់ដោយវិធានផ្ទៃក្នុង និងសេចក្ដីណែនាំអនុវត្ត។ ជាទូទៅ ភាគីពុំបានជំទាស់ទៅនឹងការបន្ថែមនេះទេ។ អង្គជំនុំជម្រះតុលាការកំពូលបានទទួលស្គាល់លក្ខណៈពិសេសនៃសាលក្រមអង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងទំហំ និងភាពស្មុគស្មាញទាំងនៅចំពោះមុខ អ.វ.ត.ក. និងតុលាការព្រហ្មទណ្ឌអន្តរជាតិដែលមានការជំនុំជម្រះទំហំធំប្រហាក់ប្រហែលគ្នា។ ជាពិសេស អង្គជំនុំជម្រះបានកត់សម្គាល់ទៅលើកំណត់ត្រានៃការជំនុំជម្រះយ៉ាងវែងក្នុងសំណុំរឿង ០០២/០២ ចំនួនសាក្សីផ្ដល់សក្ខីកម្មជាច្រើននាក់ វត្ថុតាងនានាបង្ហាញនៅពេលជំនុំជម្រះ ទំហំនៃពេលវេលា និងភូមិសាស្ត្រទូលំទូលាយនៃបទចោទ និងបញ្ហាថ្មីៗដែលបានកើតឡើង[33]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា កាលៈទេសៈពិសេសមានអត្ថិភាពដែលតម្រូវឱ្យមានការបន្ថែមពេលវេលា និងចំនួនទំព័រ។

15. ទោះជាយ៉ាងនេះក្ដី អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា សំណើរបស់ ខៀវ សំផន មានលក្ខណៈច្រើនហួសហេតុពេក។ ការបង្ហាញតាមរយៈកំហុសដែលចោទប្រកាន់នៅក្នុងសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន ឃើញថា ទឡ្ហីករណ៍បណ្ដឹងសាទុក្ខមានចំនួនច្រើន និងទូលំទូលាយ និងតម្រូវឱ្យមានពេលវេលា និងចំនួនទំព័រគ្រប់គ្រាន់ក្នុងការលើកបណ្ដឹងសាទុក្ខប្រកបដោយអត្ថន័យ[34]។ ទោះបីជាយ៉ាងណា អង្គជំនុំជម្រះបញ្ជាក់ថា ភាពខ្លាំងនៃសារណាបណ្ដឹងសាទុក្ខមិនមែនអាស្រ័យលើប្រវែងសរុប ឬចំនួនទឡ្ហីករណ៍ដែលបានលើកឡើងនោះទេ។ គុណភាពនៃសារណា អាស្រ័យទៅលើភាពច្បាស់លាស់នៃអំណះអំណាង និងការលើកមូលដ្ឋានគាំទ្រនៃទឡ្ហីករណ៍ដែលស្របតាមបទដ្ឋានតម្រូវ[35]។ យោង

[33] សេចក្ដីសម្រេចលើសំណើរបស់ នួន ជា និង ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រលើសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៩ ឯកសារលេខ F43 កថាខណ្ឌ ៨។

[34] *សូមមើល* សេចក្ដីសម្រេចលើសំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់សារណាបណ្ដឹងសាទុក្ខ និងសារណាតប ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤ ឯកសារលេខ F9 កថាខណ្ឌ ១៣។

[35] *សូមមើល ឧ. រឿងក្ដី រដ្ឋអាជ្ញាទល់នឹង Šainović និងជនទៃទៀត* សំណុំរឿងលេខ IT-05-87-A "សេចក្ដីសម្រេចលើសំណើរបស់មេធាវីការពារក្ដីសុំបន្ថែមចំនួនពាក្យ" អង្គជំនុំជម្រះឧទ្ធរណ៍ ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៩ ទំព័រ ៤។ *រឿងក្ដី រដ្ឋអាជ្ញាទល់នឹង Šainović និងជនទៃទៀត* សំណុំរឿងលេខ IT-05-87-A "សេចក្ដីសម្រេចលើសារណារួមរបស់ Nikola Šainović និង Dragoljub Ojdanić សុំបន្ថែមចំនួនពាក្យ" អង្គជំនុំជម្រះឧទ្ធរណ៍ ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៩ ទំព័រ ៤។ *រឿងក្ដី រដ្ឋអាជ្ញា*

តាមសំអាងហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់ថា ការគណនារបស់ ខៀវ សំផន ដែលបាន ផ្អែកទៅលើការប្រៀបធៀបជាមូលដ្ឋានចំពោះពេលវេលា និងចំនួនទំព័រដែលបានផ្តល់ឱ្យ សម្រាប់សារណាបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១[36] ជាពិសេស មានលក្ខណៈសមស្របនោះឡើយ។

16. តាមការស្ទង់មតិយោបល់នៃការអនុវត្តអន្តរជាតិ បង្ហាញពីនិន្នាការរបស់តុលាការព្រហ្មទណ្ឌកម្រិតអន្តរជាតិ ក្នុងការផ្តល់ពេលវេលា និងចំនួនទំព័រទៅឱ្យម្ចាស់បណ្តឹងសាទុក្ខដើម្បីលើកសារណានៅបណ្តឹងសាទុក្ខ តិចជាងអ្វីដែល ខៀវ សំផន កំពុងស្នើសុំបច្ចុប្បន្ន[37]។ ដោយសារអង្គជំនុំជម្រះតុលាការកំពូលយល់

---

*ទល់នឹង Šainović និងជនទៃទៀត* សំណុំរឿងលេខ IT-05-87-A "សេចក្តីសម្រេចលើសំណើរបស់ Streten Lukić សុំពិចារណាឡើងវិញនូវសេចក្តីសម្រេចលើសំណើសុំបន្ថែមចំនួនពាក្យ" អង្គជំនុំជម្រះឧទ្ធរណ៍ ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០៩ ទំព័រ ៣។ *រឿងក្តី រដ្ឋអាជ្ញាទល់នឹង Stanišić និង Župljanin* សំណុំរឿងលេខ IT-08-91-A "សេចក្តីសម្រេចលើសំណើរបស់ Mićo Stanišić និង Stojan Župljanin សុំធ្វើការផ្ទៀងផ្ទាត់អំពីពេលវេលា និងការកម្រិតចំនួនទំព័រក្នុងការដាក់សារណាបណ្តឹងសាទុក្ខ" អង្គជំនុំជម្រះឧទ្ធរណ៍ ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៣ ទំព័រ ៤។ *រឿងក្តី រដ្ឋអាជ្ញាទល់នឹង Prlić និងជនទៃទៀត* សំណុំរឿងលេខ IT-04-74-A "សេចក្តីសម្រេចលើសំណើសុំបន្ថែមពេលវេលាដាក់សារណាបណ្តឹងសាទុក្ខ និងការអនុញ្ញាតបន្ថែមលើសការកម្រិតចំនួនពាក្យ" អង្គជំនុំជម្រះឧទ្ធរណ៍ ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៣ កថាខណ្ឌ ១៦។ *រឿងក្តី រដ្ឋអាជ្ញាទល់នឹង Karadžić*, សំណុំរឿងលេខ MICT-13-55-A "សេចក្តីសម្រេចលើសំណើសុំបន្ថែមចំនួនពាក្យ" អង្គជំនុំជម្រះឧទ្ធរណ៍ ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១៦ ទំព័រ ២។

[36] សំណើរបស់ ខៀវ សំផន កថាខណ្ឌ ១៦ (ពិភាក្សាអំពីទំហំជារួម និងចំនួនជើងទំព័រ អង្គហេតុ និងការដាក់ពិរុទ្ធភាពធ្វើឡើងនៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ធៀបទៅនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២/០១)។ *សូមមើលផងដែរ* សំណើរបស់មេធាវីការពារក្តី ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រ ដើម្បីដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៩ ឯកសារ F39/1.1 កថាខណ្ឌ ១៧ ដល់ ២៣។ សេចក្តីសម្រេចលើសំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់សារណាបណ្តឹងសាទុក្ខ និងសារណាតប ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤ ឯកសារលេខ F9 (អនុញ្ញាតឱ្យ ខៀវ សំផន និង នួន ជា ដាក់សារណាបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមចំនួន ៦២៣ ទំព័រ ក្នុងរយៈពេល ៩០ ថ្ងៃ បន្ទាប់ពីសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ)។ សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំបន្ថែមពេលវេលា និងចំនួនទំព័រក្នុងការឆ្លើយតប ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារលេខ F13/2 (សម្រេចថា នួន ជា អាចដាក់សារណាបណ្តឹងសាទុក្ខចំនួន ២៧០)។

[37] *សូមមើល ឧ. រឿងក្តី រដ្ឋអាជ្ញាទល់នឹង Karadžić* សំណុំរឿងលេខ MICT-13-55-A "សេចក្តីសម្រេចលើសំណើសុំបន្ថែមចំនួនទំព័រ" អង្គជំនុំជម្រះឧទ្ធរណ៍ ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១៦ (អនុញ្ញាតឱ្យ Karadžić ដាក់សារណាបណ្តឹងសាទុក្ខចំនួន ៧៥.០០០ ពាក្យ ឬ ប្រហាក់ប្រហែល ២៥០ ទំព័រ ប្រឆាំងនឹងសាលក្រមចំនួន ២.៥៩០ ទំព័រ)។ *រឿងក្តី រដ្ឋអាជ្ញាទល់នឹង Karadžić* សំណុំរឿងលេខ MICT-13-55-A "សេចក្តីសម្រេចលើសំណើរួមសុំបន្ថែមពេលវេលាដាក់សារណាបណ្តឹងសាទុក្ខ និងសារណាតប" អង្គជំនុំជម្រះឧទ្ធរណ៍ ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១៦ (អនុញ្ញាតឱ្យ Karadžić ដាក់សារណាបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ២.៥៩០ ទំព័រក្នុងរយៈពេល ១៣៥ ថ្ងៃ គិតចាប់ថ្ងៃជូនដំណឹងអំពីបណ្តឹងសាទុក្ខ)។ *រឿងក្តី រដ្ឋអាជ្ញាទល់*

*នឹង Taylor* សំណុំរឿងលេខ SCSL-03-01-A "សេចក្តីសម្រេចលើសំណើរបស់អយ្យការ និងមេធាវីការពារក្តីសុំបន្ថែមពេលវេលា និងចំនួនទំព័រដាក់សារណាជាលាយលក្ខណ៍អក្សរដោយអនុលោមតាមវិធាន ១១១ ១១២ និង ១១៣" អង្គជំនុំជម្រះឧទ្ធរណ៍ ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១២ (សម្រេចថា ជនជាប់ចោទ Taylor អាចដាក់សារណាបណ្តឹងសាទុក្ខ និងសារណាតបសរុបចំនួន ៤០០ ទំព័រ ប្រឆាំងនឹងសាលក្រមចំនួន ២.៥៣២ ទំព័រ)។ *រឿងក្តី រដ្ឋអាជ្ញាទល់នឹង Taylor* សំណុំរឿងលេខ SCSL-03-01-A "សេចក្តីសម្រេចលើសំណើសុំរបស់មេធាវីការពារក្តីឱ្យពិចារណាឡើងវិញ ឬពិនិត្យឡើងវិញនូវ'សេចក្តីសម្រេចស្តីពីសំណើរបស់អយ្យការ និងមេធាវីការពារក្តីសុំបន្ថែមពេលវេលា និងទំព័រ តាមវិធាន ១១១ ១១២ និង ១១៣' និងដីកាចុងក្រោយលើការបន្ថែមពេលវេលាសម្រាប់ដាក់សារណា" អង្គជំនុំជម្រះឧទ្ធរណ៍ ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១២ (សន្និដ្ឋានថាជនជាប់ចោទ Taylor អាចដាក់សារណាបណ្តឹងសាទុក្ខរបស់ខ្លួនក្នុងរយៈពេល ៧៤ ថ្ងៃ គិតចាប់ពីពេលដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ)។ *រឿងក្តី រដ្ឋអាជ្ញាទល់នឹង Mladić* សំណុំរឿងលេខ MICT-13-56-A "សេចក្តីសម្រេចលើសំណើរបស់ Ratko Mladić សុំបន្ថែមពេលវេលា និងចំនួនពាក្យ" អង្គជំនុំជម្រះឧទ្ធរណ៍ ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១៨ (សម្រេចថា Mladić អាចដាក់សារណាបណ្តឹងសាទុក្ខចំនួន ៧៥.០០០ ពាក្យ ឬប្រហែល ២៥០ ទំព័រប្រឆាំងទៅនឹងសាលក្រមចំនួន ២.៤៧៨ ក្នុងរយៈពេល ១៣៥ ថ្ងៃគិតចាប់ពីពេលជូនដំណឹងអំពីបណ្តឹងសាទុក្ខ)។ *រឿងក្តី រដ្ឋអាជ្ញាទល់នឹង Šainović និងជនទៃទៀត* សំណុំរឿងលេខ IT-05-87-A "សេចក្តីសម្រេចលើសំណើរួមរបស់មេធាវីការពារក្តីសុំបន្ថែមពេលវេលាដាក់សារណាបណ្តឹងសាទុក្ខ" អង្គជំនុំជម្រះឧទ្ធរណ៍ ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៩ (បានអនុញ្ញាតឱ្យជនជាប់ចោទប្រាំនាក់ដាក់សារណាបណ្តឹងសាទុក្ខរៀងៗខ្លួនប្រឆាំងនឹងសាលក្រមចំនួន ១.៧២៤ ទំព័ររយៈពេល ១២០ ថ្ងៃចាប់ពេលដាក់សេចក្តីជូនដំណឹងនៃបណ្តឹងសាទុក្ខ)។ *រឿងក្តី រដ្ឋអាជ្ញាទល់នឹង Šainović និងជនទៃទៀត* សំណុំរឿងលេខ IT-05-87-A "សេចក្តីសម្រេចលើសំណើសុំបន្ថែមចំនួនពាក្យ" អង្គជំនុំជម្រះឧទ្ធរណ៍ ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៩ (សម្រេចថា Pavkokić និង Lazarević អាចដាក់សារណាបណ្តឹងសាទុក្ខចំនួន ៤៥.០០០ ពាក្យ ឬប្រហែល ១៥០ ទំព័រ ប្រឆាំងនឹងសាលក្រមចំនួន ១.៧២៤ ហើយ Lukić អាចដាក់សារណាបណ្តឹងសាទុក្ខចំនួន ៦០.០០០ ឬប្រហែល ២០០ ទំព័រប្រឆាំងនឹងសាទុក្ខនេះដែរ)។ *រឿងក្តី រដ្ឋអាជ្ញាទល់នឹង Šainović និងជនទៃទៀត* សំណុំរឿងលេខ IT-05-87-A "សេចក្តីសម្រេលើសំណើរួមរបស់ Nikola Šainović's និង Dragoljub Ojdanić សុំបន្ថែមចំនួនពាក្យ" អង្គជំនុំជម្រះឧទ្ធរណ៍ ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៩ (បានអនុញ្ញាតឱ្យ Šainović និង Ojdanić ដាក់សារណាបណ្តឹងសាទុក្ខ ៤៥.០០០ ពាក្យ ឬប្រហែល ១៥០ ទំព័រប្រឆាំងនឹងសាលក្រមចំនួន ១.៧២៤ ទំព័រ)។ *រឿងក្តី រដ្ឋអាជ្ញាទល់នឹង Prlić និងជនទៃទៀត* សំណុំរឿងលេខ IT-04-74-A "សេចក្តីសម្រេចលើសំណើរបស់ម្ចាស់បណ្តឹងសាទុក្ខសុំបន្ថែមពេលវេលា និងចំនួនពាក្យ" អង្គជំនុំជម្រះឧទ្ធរណ៍ ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១៤ (បានអនុញ្ញាតឱ្យម្ចាស់បណ្តឹងសាទុក្ខចំនួនប្រាំមួយនាក់ដាក់សារណាបណ្តឹងសាទុក្ខចំនួន ៥០.០០០ ពាក្យ ឬ ប្រហែល ១៦៥ ទំព័រ ប្រឆាំងនឹងសាលក្រមចំនួន ២.៧០០ ទំព័រ និងសម្រេចថា Pušić អាចដាក់សារណាបណ្តឹងសាទុក្ខក្នុងរយៈពេល ៥៦៤ ថ្ងៃ ចាប់ពីពេលដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ និងសន្និដ្ឋានថា Praljak អាចដាក់សារណាបណ្តឹងសាទុក្ខរយៈពេល ៥៦៣ ថ្ងៃចាប់ពីពេលជូនដំណឹងអំពីបណ្តឹងសាទុក្ខ និងអនុញ្ញាតឱ្យ Ćorić, Stojić, និង Petković បន្ថែមពេលវេលាដាក់សារណាបណ្តឹងសាទុក្ខក្នុងរយៈពេល ១៦១ ថ្ងៃចាប់ពីពេលជូនដំណឹងអំពីបណ្តឹងសាទុក្ខ និងអនុញ្ញាតឱ្យ Prlić បន្ថែមពេលវេលាដាក់សារណាបណ្តឹងសាទុក្ខ ក្នុងរយៈពេល ១៦០ ថ្ងៃចាប់ពីពេលជូនដំណឹងអំពីបណ្តឹងសាទុក្ខ)។ *រឿងក្តីរដ្ឋអាជ្ញាទល់នឹង Nyiramasuhuko និងជនទៃទៀត* សំណុំរឿងលេខ ICTR-98-42-A "សេចក្តីសម្រេចលើសំណើរបស់ Nyiramasuhuko, Ntahobali, Kanyabashi និង Ndayambaje សុំបន្ថែមចំនួនពាក្យសម្រាប់សារណាបណ្តឹងសាទុក្ខ" អង្គជំនុំជម្រះឧទ្ធរណ៍ ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១២ (អនុញ្ញាតឱ្យ

ឃើញថា ឧទាហរណ៍នេះជាការបកស្រាយពន្យល់ ដូច្នេះ អង្គជំនុំជម្រះ ពុំត្រូវបានចងកាតព្វកិច្ចដោយសារការអនុវត្តនៃយុត្តាធិការតុលាការណាមួយឡើយ។ ដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខចំពោះមុខ អ.វ.ត.ក. ខុសប្លែកពីតុលាការព្រហ្មទណ្ឌអន្តរជាតិដទៃទៀត ក្នុងការកំណត់យុត្តាធិការបណ្តឹងសាទុក្ខភ្លាមៗចំនួនបួនប្រភេទខុសគ្នា និងក្នុងការដាក់ការពិនិត្យនៃសេចក្តីសម្រេចដទៃទៀតរបស់អង្គជំនុំជម្រះសាលាដំបូង ទៅក្នុងដំណាក់កាលដែលសាលក្រមលើអង្គសេចក្តីត្រូវបានធ្វើបណ្តឹងសាទុក្ខ[38]។ បន្ថែមលើកំហុសដែលចោទប្រកាន់ចំនួន ១.៨២៤ នៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង (កំហុសមួយចំនួនដែល ខៀវ សំផន បានទទួលស្គាល់ថា អាចត្រួតគ្នា[39]) ខៀវ សំផន បានកំណត់សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង(ដោយត្រួសៗ)ចំនួន ៣៥៥ សម្រាប់ប្តឹងសាទុក្ខ[40]។ អង្គជំនុំជម្រះរំលឹក ខៀវ សំផន ថា គាត់ត្រូវបង្ហាញព្យសនកម្មប៉ះពាល់យូរអង្វែងទាក់ទងទៅនឹងទឡ្ហីករណ៍មួយ ឬច្រើនដែលអនុញ្ញាតឱ្យធ្វើបណ្តឹង

---

Ntahobali និង Nyiramasuhuko ដាក់សារណាចំនួន ៨០.០០០ ពាក្យ ឬប្រហែល ២៧៥ ទំព័រ ប្រឆាំងនឹងសាលក្រមចំនួន ១.៤៦៨ ទំព័រ និងអនុញ្ញាតឱ្យ Ndayambaje ដាក់សារណាបណ្តឹងសាទុក្ខចំនួន ៥០.០០០ ពាក្យ ឬប្រហែល ១៦៥ ទំព័រប្រឆាំងនឹងសាក្រមនេះ និងបានអនុញ្ញាត Kanyabashi ដាក់សារណាបណ្តឹងសាទុក្ខចំនួន ៤០.០០០ ឬប្រហែល ១៣០ ទំព័រ)។ *សូមមើលផងដែរ រឿងក្តីរដ្ឋអាជ្ញាទល់នឹង Lubanga* សំណុំរឿងលេខ ICC-01/04-01/06 A5 "សេចក្តីសម្រេចលើសំណើរបស់ Mr Lubanga សុំបន្ថែមចំនួនទំព័រ" អង្គជំនុំជម្រះឧទ្ធរណ៍ ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១២ (អនុញ្ញាតតាមសំណើរបស់ Lubanga សុំដាក់សារណាបណ្តឹងសាទុក្ខចំនួន ១២០ ទំព័រប្រឆាំងនឹងសេចក្តីសម្រេចដាក់ពិរុទ្ធភាពចំនួន ៥៩៣ ទំព័រ)។ *រឿងក្តីរដ្ឋអាជ្ញាទល់នឹង Bemba* សំណុំរឿងលេខ ICC-01/05-01/08 A "សេចក្តីសម្រេចលើសំណើរបស់ Mr Bemba សុំបន្ថែមពេលវេលាសម្រាប់ដាក់ឯកសារគាំទ្របណ្តឹងសាទុក្ខ" អង្គជំនុំជម្រះឧទ្ធរណ៍ ថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ២០១៦ (អនុញ្ញាតឱ្យ Bemba ដាក់សារណាបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចដាក់ពិរុទ្ធភាពចំនួន ៣៦៤ ទំព័រ រយៈពេល ១៨០ ថ្ងៃបន្ទាប់ពីការជូនដំណឹងនៃសេចក្តីសម្រេចនោះ)។ *រឿងក្តីរដ្ឋអាជ្ញាទល់នឹង Bemba* សំណុំរឿង ICC-01/05-01/08 A "សេចក្តីសម្រេចលើសំណើរបស់ Mr. Bemba សុំបន្ថែមចំនួនទំព័រសម្រាប់ដាក់ឯកសារគាំទ្របណ្តឹងសាទុក្ខ" អង្គជំនុំជម្រះឧទ្ធរណ៍ ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៦ (សម្រេចថា Bemba អាចដាក់សារណាបណ្តឹងសាទុក្ខចំនួន ២០០ ទំព័រប្រឆាំងនឹងសេចក្តីសម្រេចដាក់ពិរុទ្ធភាពចំនួន ៣៦៤ ទំព័រ)។

[38] សេចក្តីសម្រេចលើសំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់សារណាបណ្តឹងសាទុក្ខ និងសារណាតប ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤ ឯកសារលេខ F9 កថាខណ្ឌ ១៦។ *សូមមើលផងដែរ* វិធាន ១០៤(៤) នៃវិធានផ្ទៃក្នុង។

[39] សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (០០២/០២) កថាខណ្ឌ ១២ ("កំហុសដែលបានរកឃើញ មិនមែនបង្ហាញស្របតាមផែនការដែលអាចប្រើប្រាស់បានជាផែនការសម្រាប់សារណាបណ្តឹងសាទុក្ខនោះឡើយ ប៉ុន្តែត្រឹមបង្ហាញជាធម្មតាដែលមាននៅក្នុងសាលក្រមជាលាយលក្ខណ៍អក្សរចុងក្រោយ។ អាស្រ័យហេតុនេះ អាចកើតមានថា កំហុសមួយចំនួនអាចត្រួតគ្នា ប៉ុន្តែ មេធាវីការពារក្តីពុំមានពេលវេលាធ្វើការពិនិត្យផ្ទួងផ្ទៀងផ្ទែកនីមួយៗបានឡើយ")។ ការឆ្លើយតបរបស់ ខៀវ សំផន កថាខណ្ឌ ១២ (ជើងទំព័រ ២៤)។

[40] សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១៥។

សាទុក្ខប្រឆាំងនឹងសាលក្រម[41] និងថា ដំណើរការនីតិវិធីលើបណ្ដឹងសាទុក្ខមានគោលបំណងកែតម្រូវកំហុសផ្នែកច្បាប់ និងផ្ទៀងផ្ទាត់លើបញ្ហាថាតើ បទដ្ឋានស្ដីពីភស្តុតាងត្រូវបានបំពេញ ដែរ ឬយ៉ាងណា មិនមែនជំនុំជម្រះលើបញ្ហាទាំងនោះ*សាជាថ្មី*នោះឡើយ[42]។

17. អាស្រ័យហេតុនេះ អង្គជំនុំជម្រះពិចារណាឃើញថា សារណាបណ្ដឹងសាទុក្ខដែលមិនលើសពី ៧៥០ ទំព័រ ជាចំនួនគ្រប់គ្រាន់សម្រាប់ ខៀវ សំផន លើកឡើងនូវទឡ្ហីករណ៍នៃបណ្ដឹងសាទុក្ខជារួមយ៉ាងច្បាស់លាស់។ ផ្អែកលើកាលៈទេសៈបច្ចុប្បន្ន អង្គជំនុំជម្រះទទួលស្គាល់ថា ការដាក់សារណាបណ្ដឹងសាទុក្ខជាភាសាបារាំង ឬអង់គ្លេស ដែលការបកប្រែជាភាសាខ្មែរដាក់តាមក្រោយឱ្យបានឆាប់បំផុតតាមដែលធ្វើទៅបាននោះ អាចទទួលយកបាន។

## ការពន្លឿនកិច្ចដំណើរការនីតិវិធី

18. ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះតុលាការកំពូល"មិនអើពើ"អំពីសិទ្ធិរបស់គាត់"ដោយគិតតែពីផ្ដល់អាទិភាពទៅលើភាពចាំបាច់ក្នុងការធានាឱ្យកិច្ចដំណើរការនីតិវិធីបានឆាប់រហ័ស"។ គាត់បានលើកឡើងថា សិទ្ធិទទួលបានកិច្ចដំណើរការនីតិវិធីឆាប់រហ័ស ពុំមែនជាកិច្ចដំណើរការដែលបានធានាដោយក្របខ័ណ្ឌការងារនៅ អ.វ.ត.ក. ឬបទដ្ឋានអន្តរជាតិនោះទេ និងថា ការបារម្ភតែពី"ភាពឆាប់រហ័ស"ពុំគប្បីធ្វើឱ្យគាត់បាត់សិទ្ធិទទួលបានពេលវេលា និងសម្ភារៈគ្រប់គ្រាន់ក្នុងការរៀបចំមធ្យោបាយការការពារខ្លួនរបស់គាត់ដែរ[43]។

[41] សេចក្ដីសម្រេចលើសំណើរបស់សុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់ដាក់សារណាបណ្ដឹងសាទុក្ខ និងសារណាតប ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤ កថាខណ្ឌ ១៦។

[42] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០២/០១ ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ឯកសារលេខ F36 កថាខណ្ឌ ៩៤ (កត់សម្គាល់ឃើញថា "នៅក្នុងបរិបទ អ.វ.ត.ក. ដោយសារកង្វះធនធាន បានរារាំងការប្រកាសពិរុទ្ធភាព និងទោសនៅដំណាក់កាលបណ្ដឹងឧទ្ធរណ៍ ដែល [...] បង្ហាញនូវការផ្ដោតទៅលើការពន្លឿនកិច្ចដំណើរការនីតិវិធី ដោយសារតួនាទីក្នុងការកែតម្រូវនៅដំណាក់កាលឧទ្ធរណ៍ត្រូវបានកម្រិត និងលុបចោលក្នុងគោលបំណងការពារផលប្រយោជន៍ជនជាប់ចោទ") (សេចក្ដីបញ្ជាក់បន្ថែម)។

[43] សំណើរបស់ ខៀវ សំផន កថាខណ្ឌ ២៣ ដល់ ២៥។

19. អង្គជំនុំជម្រះតុលាការកំពូល និងអង្គជំនុំជម្រះដទៃទៀតនៃ អ.វ.ត.ក.[44] បានបញ្ជាក់ស្របគ្នាថា អង្គជំនុំជម្រះត្រូវថ្លឹងថ្លែងអំពីអត្ថប្រយោជន៍របស់ភាគីជាមួយនឹងតម្រូវការចាំបាច់សម្រាប់កិច្ចដំណើរការនីតិវិធីប្រកបដោយប្រសិទ្ធភាព និងឆាប់រហ័ស[45]។ ការអនុវត្តដែលធ្វើឱ្យមានតុល្យភាពនេះ មានចែងនៅក្នុងមាត្រា ១៤ និង ១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ(ដែលកម្ពុជាជាភាគី) និងត្រូវបានបញ្ចូលទៅក្នុងក្របខ័ណ្ឌការងាររបស់ អ.វ.ត.ក. តាមរយៈកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា[46] និងត្រូវបានកំណត់ត្រឹមត្រូវតាមច្បាប់ដោយច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា[47] និងត្រូវបានទទួលយកជាគោលការណ៍គ្រឹះនៃនីតិវិធីរបស់ អ.វ.ត.ក.

---

[44] *សូមមើលឧ.* សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ ឯកសារលេខ D427/1/30 កថាខណ្ឌ ៥០ (សម្រេចថា "សិទ្ធិមួយក្នុងចំណោមនោះដែលម្ចាស់បណ្តឹងសាទុក្ខទទួលបានគឺការជំនុំជម្រះឆាប់រហ័ស")។ អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូង "សំណើរបស់សហព្រះរាជអាជ្ញាសុំពន្យារពេលដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោល និងការពន្យារពេលចាប់ផ្តើមសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលក្នុងសំណុំរឿង ០០២/០២" ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៧ ឯកសារលេខ E457/6 កថាខណ្ឌ ១១ (កត់សម្គាល់ឃើញថា អង្គជំនុំជម្រះមានកាតព្វកិច្ច"ធានាថា កិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០២ [...] ត្រូវបានបញ្ចប់យ៉ាងឆាប់រហ័ស និងទាន់ពេលបំផុត)។

[45] *សូមមើលឧ.* សេចក្តីសម្រេចលើការបំបែកសំណុំរឿង ០០២ និងវិសាលភាព ០០២/០២ ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៤ ឯកសារលេខ E301/9/1 កថាខណ្ឌ ៣៦ (កត់សម្គាល់ឃើញថា "អង្គជំនុំជម្រះប្រឈមនឹងការងារលំបាកក្នុងការថ្លឹងថ្លែងនូវអត្ថប្រយោជន៍ក្នុងការទទួលបានកិច្ចដំណើរការនីតិវិធីឆាប់រហ័ស និងប្រសិទ្ធភាព ខណៈនោះដែរត្រូវពិចារណាទៅលើអត្ថប្រយោជន៍ដែលមានចែងរបស់ភាគី)។ សេចក្តីសម្រេចលើសំណើសុំបន្ថែមចំនួនទំព័រធ្វើបណ្តឹងសាទុក្ខ និងពេលវេលាឆ្លើយតប ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារលេខ F13/2 កថាខណ្ឌ ១៥ (សម្រេចថា ការកម្រិតនៃនីតិវិធីត្រូវ"សម្របសម្រួលដោយផ្អែកលើទៅលើគោលការណ៍នៃប្រសិទ្ធភាពតុលាការ)។ សេចក្តីសម្រេចលើសំណើរបស់ នួន ជា និង ខៀវ សំផន សុំបន្ថែមពេលវេលា និងទំព័រលើសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៩ ឯកសារលេខ F43 កថាខណ្ឌ ១០ (ពិចារណាឃើញថា "សេដ្ឋកិច្ចរបស់តុលាការតម្រូវឱ្យអង្គជំនុំជម្រះតុលាការកំពូលថ្លឹងថ្លែងកត្តាមួយចំនួនរួមទាំងធនធាន និងការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនៃដំណើរការនីតិវិធី")។ សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំពិនិត្យឡើងវិញលើសេចក្តីសម្រេចស្តីពីការបន្ថែមពេលវេលា និងចំនួនទំព័រលើសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១៩ ឯកសារលេខ F44/1 ទំព័រ ៣ (លើកឡើងថា អង្គជំនុំជម្រះ "បានដឹងពីតម្រូវការក្នុងការធានាកិច្ចដំណើរការនីតិវិធីឱ្យបានឆាប់រហ័សដោយផ្អែកតាមក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក. និងបទដ្ឋានអន្តរជាតិ")។

[46] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាពាក់ព័ន្ធទៅនឹងការកាត់សេចក្តីក្រោមច្បាប់កម្ពុជានូវបទឧក្រិដ្ឋដែលបានប្រព្រឹត្តឡើងក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ ចុះហត្ថលេខានៅថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៣ និងចូលជាធរមាននៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៥ មាត្រា ១២(២)។

[47] ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាសម្រាប់កាត់សេចក្តីបទឧក្រិដ្ឋ ដែលបានប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០១ ដែលមានការរួមបញ្ចូលនូវវិសោធនកម្មដែលបានផ្សព្វផ្សាយឱ្យប្រើប្រាស់នៅថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ ("ច្បាប់ អ.វ.ត.ក.") មាត្រា ៣៣ *ថ្មី* (អង្គជំនុំជម្រះសាលាដំបូង

[48]។ តុលាការព្រហ្មទណ្ឌអន្តរជាតិដទៃទៀតបានអនុវត្តតាមវិធីសាស្ត្រប្រហាក់ប្រហែលគ្នានេះ នៅពេលសម្រេចលើសំណើសុំពន្យារពេល និង/ឬ ចំនួនទំព័រ ក្នុងការដាក់សារណាលើបណ្តឹងសាទុក្ខ[49]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះបដិសេធអំណះអំណាងរបស់ ខៀវ សំផន ទាក់ទងចំណុចដែលថា កិច្ចដំណើរការនីតិវិធីឆាប់រហ័សពុំមែនជាការពិចារណាត្រឹមត្រូវតាមផ្លូវតុលាការនោះ។

20. អានុភាពជាក់ស្តែងនៃការផ្តល់ការបន្ថែមរយៈពេល ៨,៥ ខែ គឺជាការដាក់សារណាបណ្តឹងសាទុក្ខតែមួយភាសាប៉ុណ្ណោះដល់ត្រឹមពាក់កណ្តាលខែ ឧសភា ឆ្នាំ ២០២០ ដែលការបកប្រែសារណាយ៉ាងវែងនេះត្រូវដាក់តាមក្រោយបន្ទាប់ពីនោះ។ បើទោះបីជាក្នុងករណីពុំមានការបន្ថែមណាមួយទៅលើសារណាតប និងចម្លើយតប រយៈពេលនេះ គឺវែងឆ្ងាយហួសហេតុ ជាពិសេស ដោយសារពេលវេលាសម្រាប់ដាក់ឯកសារ នឹងចាប់ផ្តើមគិតតែនៅពេលណាការបកប្រែសារណាបណ្តឹងសាទុក្ខ ឬសារណាតប ត្រូវបានជូន

---

ត្រូវប្រព្រឹត្តទៅឱ្យបានត្រឹមត្រូវ និងឆាប់រហ័ស ដោយមានការគោរពយ៉ាងពេញលេញនូវសិទ្ធិរបស់ជន ត្រូវចោទ និងមានការការពារឱ្យបានត្រឹមត្រូវចំពោះជនរងគ្រោះ និងសាក្សី។ *សូមមើលផងដែរ* ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. មាត្រា ៣៧ *ថ្មី* ("ប្រការដែលបានចែងនៅក្នុងមាត្រា ៣៣ [...] ត្រូវអនុវត្ត*ដូចគ្នា* ចំពោះការជំនុំជម្រះក្តីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញនៃតុលាការកំពូល")។

[48] *សូមមើលឧ.* វិធាន ២១(៤) នៃវិធាផ្ទៃក្នុង ("កិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក. ត្រូវបញ្ចប់ក្នុងពេលវេលាសមរម្យ")។ វិធាន ៧៩(១) នៃវិធានផ្ទៃក្នុង ("ដើម្បីសម្រួលដល់ការអនុវត្តកិច្ចដំណើរការនីតិវិធីបានត្រឹមត្រូវ និងឆាប់រហ័ស អង្គជំនុំជម្រះអាច [...] បើកកិច្ចប្រជុំរៀបចំសវនាការ")។

[49] *សូមមើលឧ. រឿងក្តីរដ្ឋអាជ្ញាទល់នឹង Karadžić* សំណុំរឿងលេខ MICT-13-55-A "សេចក្តីសម្រេចលើសំណើរួមសុំបន្ថែមពេលវេលា និងចំនួនទំព័រ ដាក់សារណាបណ្តឹងសាទុក្ខ និងសារណាតប" អង្គជំនុំជម្រះឧទ្ធរណ៍ ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១៦ ទំព័រ ២។ *រឿងក្តីរដ្ឋអាជ្ញាទល់នឹង Mladić* សំណុំរឿងលេខ MICT-13-56-A "សេចក្តីសម្រេចលើសំណើរបស់ Ratko Mladić សុំបន្ថែមពេលវេលា និងចំនួនពាក្យ" អង្គជំនុំជម្រះឧទ្ធរណ៍ ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១៨។ *សូមមើលផងដែរ រឿងក្តីរដ្ឋអាជ្ញាទល់នឹង Šainović និងជនដទៃទៀត* សំណុំរឿងលេខ IT-05-87-A "សេចក្តីសម្រេចលើសំណើរួមរបស់មេធាវីការពារក្តីសុំបន្ថែមពេលវេលាដាក់សារណាបណ្តឹងសាទុក្ខ" អង្គជំនុំជម្រះឧទ្ធរណ៍ ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៩ ទំព័រ ៣ (កត់សម្គាល់ឃើញថា "កាលបរិច្ឆេទរបស់តុលាការសម្រាប់ការដាក់សារណាអនុលោមតាមវិធាន ១១១(ក) មានសារៈសំខាន់ក្នុងការធានាបាននូវការរៀបចំរឿងក្តីបានឆាប់រហ័ស") (សេចក្តីបញ្ជាក់បន្ថែម)។ *រឿងក្តីរដ្ឋអាជ្ញាទល់នឹង Stanišić និង Župljanin* សំណុំរឿងលេខ IT-08-91-A "សេចក្តីសម្រេចលើសំណើរបស់ Mićo Stanišić និង Stojan Župljanin សុំការកែប្រែលើការកំណត់ពេលវេលា និងចំនួនពាក្យសម្រាប់ការសារណាបណ្តឹងសាទុក្ខ" អង្គជំនុំជម្រះឧទ្ធរណ៍ ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៣ ទំព័រ ២ (ពិចារណាឃើញថា "អង្គជំនុំជម្រះត្រូវធានានូវកិច្ចដំណើរការនីតិវិធីចំពោះមុខខ្លួន ឱ្យបាន*ត្រឹមត្រូវ និងឆាប់រហ័ស*) (សេចក្តីបញ្ជាក់បន្ថែម)។ *រឿងក្តីរដ្ឋអាជ្ញាទល់នឹង Taylor* សំណុំរឿងលេខ SCSL-03-01-A "សេចក្តីសម្រេចលើសំណើរបស់អយ្យការ និងមេធាវីការពារក្តីសុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់សារណាជាលាយលក្ខណ៍អក្សរអនុលោមតាមវិធាន ១១១ ១១២ និង ១១៣" អង្គជំនុំជម្រះឧទ្ធរណ៍ ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១២ កថាខណ្ឌ ១០។

ដំណឹងប៉ុណ្ណោះ។ ផ្អែកលើកត្តារៀបរាប់ខាងលើ[50] រួមទាំងវ័យចាស់ជរារបស់ម្ចាស់បណ្តឹងសាទុក្ខ ធនធានដែលមានសម្រាប់ក្រុមមេធាវីការពារក្តីរបស់គាត់[51] និងសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការទទួលបានសាលក្រមទាន់ពេលវេលា[52] អង្គជំនុំជម្រះពិចារណាឃើញថា រយៈពេលជិតមួយឆ្នាំ (បើទោះបីមិនច្រើនជាងនេះ) ក្នុងការដាក់សារណាពេញលេញនៃបណ្តឹងសាទុក្ខ វាច្រើនហួសហេតុខុសពីប្រក្រតី។

21. អង្គជំនុំជម្រះយល់ឃើញថា ២៤០ ថ្ងៃ គិតចាប់ពីថ្ងៃដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ គ្រប់គ្រាន់សម្រាប់ ខៀវ សំផន ដាក់សារណាបណ្តឹងសាទុក្ខរបស់គាត់។

22. អង្គជំនុំជម្រះជូនដំណឹងដល់ភាគីថា យោងតាម មាត្រា ៨.៤ នៃសេចក្តីណែនាំអនុវត្ត អង្គជំនុំជម្រះនឹងអនុញ្ញាតឱ្យមានការលើកឡើងដោយផ្ទាល់មាត់លើបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៃអង្គជំនុំជម្រះសាលាដំបូងក្នុងអំឡុងពេលសវនាការលើបណ្តឹងសាទុក្ខ[53]។ អាស្រ័យហេតុនេះ ចម្លើយតបជាលាយលក្ខណ៍អក្សរ មិនអាចទទួលយកបាន។ កាលបរិច្ឆេទនៃសវនាការលើបណ្តឹងសាទុក្ខ នឹងត្រូវជូនដំណឹងដោយប្រធានអង្គជំនុំជម្រះតាមពេលវេលាសមស្រប។

## ការកំណត់ពេលវេលានៃសារណាតបរបស់ ខៀវ សំផន ទៅនឹងសារណារបស់សហព្រះរាជអាជ្ញា

### *សារណា*

23. ខៀវ សំផន បានស្នើសុំដាក់សារណាតបទៅនឹងសារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ក្នុងរយៈពេល ៤០ ថ្ងៃ បន្ទាប់ពីការដាក់សារណាបណ្តឹងសាទុក្ខរបស់ខ្លួន[54]។ គាត់បានលើកឡើងថា សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាបានបង្ហាញពីចេតនាប្តឹងសាទុក្ខលើ“បញ្ហាស្មុគស្មាញ

---

[50] *សូមមើល*ខាងលើ កថាខណ្ឌ

[51] សំណើរបស់ ខៀវ សំផន កថាខណ្ឌ ១៧ ដល់ ១៨។

[52] សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី ០០២/០១ (នួន ជា និង ខៀវ សំផន) ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារលេខ F36 (“សាលដីកាក្នុងសំណុំរឿង ០០២/០១”) កថាខណ្ឌ ៨១។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានជូនដំណឹងអង្គជំនុំជម្រះតុលាការកំពូលថា ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២៨១ បានស្លាប់ តាំងពីឆ្នាំ ២០០៧ និងថា “ដើមបណ្តឹងរដ្ឋប្បវេណីជាច្រើននាក់ទៀត ពុំមានសុខភាពមាំទាំនោះទេ ដោយសារជំងឺ ឬវ័យជរា ដែលពុំបានអាចចូលរួមក្នុងកិច្ចដំណើរការនីតិវិធី ឬវេទិការអន្តរជាតិបាន”។ *សូមមើល* សារណាតបរបស់សហមេធាវីនាំមុខ កថាខណ្ឌ ៦។ *សូមមើលផងដែរ* សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៣។

[53] *សូមមើល* វិធាន ១០៨(៣) នៃវិធានផ្ទៃក្នុង។

[54] សំណើរបស់ ខៀវ សំផន កថាខណ្ឌ ៣២ និង ៣៨។

ថ្មីៗផ្នែកអង្គច្បាប់ និងអង្គហេតុ ដែលពុំធ្លាប់បានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល (ឬចំពោះមុខ តុលាការអន្តរជាតិ ឬតុលាការព្រហ្មទណ្ឌកម្រិតអន្តរជាតិ)”[55]។ អង្គជំនុំជម្រះរំលឹកថា សហព្រះរាជអាជ្ញាបានស្នើសុំលើកទឡ្ហីករណ៍តែមួយនៃបណ្ដឹងសាទុក្ខ គឺថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ជនរងគ្រោះបុរសនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលត្រូវបង្ខំឱ្យរួមភេទដោយគ្មានការយល់ព្រម ពុំមែនជាជនរងគ្រោះនៃអំពើអមនុស្សធម៌ដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលជាកំហុសអង្គច្បាប់ និង/ឬអង្គហេតុ[56]។ ខៀវ សំផន បានលើកឡើងថា ដោយសារគាត់ពុំត្រូវបានដាក់ពិរុទ្ធលើចំណុចនេះ ក្រុមមេធាវីការពារក្ដីរបស់គាត់ត្រូវតែបានអនុញ្ញាតផ្ដោតទៅលើទឡ្ហីករណ៍នៃបណ្ដឹងសាទុក្ខជាមុនសិនមុនពេលដោះស្រាយទឡ្ហីករណ៍នៃបណ្ដឹងសាទុក្ខដែលបានលើកឡើងដោយសហព្រះរាជអាជ្ញា[57]។

24. សហព្រះរាជអាជ្ញាពុំបានជំទាស់ទៅនឹងការបន្ថែមសមហេតុផលណាមួយសម្រាប់ ខៀវ សំផន ឆ្លើយតប ប៉ុន្តែស្នើសុំថា ការបន្ថែមដែលផ្ដល់ឱ្យមេធាវីការពារក្ដី ត្រូវមានលក្ខណៈសមាមាត្រទៅនឹងការបន្ថែមផ្ដល់ឱ្យសហព្រះរាជអាជ្ញាសម្រាប់ការដាក់សារណាតប[58]។ នៅក្នុងសំណើសុំបន្ថែម(ដែលបានដាក់ជាការឆ្លើយតបទៅនឹងសំណើរបស់ ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រ) សហព្រះរាជអាជ្ញាបានទាមទារថា យ៉ាងហោចណាស់ ៧០% នៃចំនួនទំព័រសរុបបញ្ចូលគ្នា និង ៥០% នៃចំនួនពេលវេលាសរុប គប្បីផ្ដល់ឱ្យមេធាវីការពារក្ដី[59]។ ខៀវ សំផន បានឆ្លើយតបថា សហព្រះរាជអាជ្ញាខកខានក្នុងការពន្យល់មូលហេតុដែលសហព្រះរាជអាជ្ញា គប្បីត្រូវបានផ្ដល់ជូនការបន្ថែមចំនួនទំព័រដែលបានស្នើសុំ ឬពេលវេលាដូចគ្នាដែលបានផ្ដល់ឱ្យទៅភាគីនានានៅក្នុងសំណុំរឿង ០០២/០១[60] និងថា សំណើរបស់សហព្រះរាជអាជ្ញា ពុំសមហេតុផល ដោយសារ*ក្នុងចំណោមនោះ* សារណារបស់ក្រុមមេធាវីការពារក្ដី“មានលក្ខណៈ

---

[55] សំណើរបស់ ខៀវ សំផន កថាខណ្ឌ ៣៥។

[56] សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញានៃសាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៩ ឯកសារលេខ E465/2/1 កថាខណ្ឌ ២។

[57] សំណើរបស់ ខៀវ សំផន កថាខណ្ឌ ៣៦ ដល់ ៣៧។

[58] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៨។

[59] សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ នួន ជា សុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់សារណាបណ្ដឹងសាទុក្ខ ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៩ ឯកសារលេខ F47/1 កថាខណ្ឌ ២៥ (យោងទៅលើការបន្ថែមពេលវេលា ដែលបានផ្ដល់ឱ្យទៅនឹង ខៀវ សំផន និង នួន ជា)។

[60] សារណាតបរបស់ ខៀវ សំផន ទៅនឹងសហព្រះរាជអាជ្ញា កថាខណ្ឌ ៨ ដល់ ១៣។

ត្រួតគ្នាយ៉ាងច្រើន"[61] និងថា នៅគ្រប់កាលៈទេសៈ សំណើសុំរបស់សហព្រះរាជអាជ្ញា"ដែលមានលក្ខណៈ វិវត្តន៍" គឺយឺតពេល[62]។ នៅក្នុងសំណើសុំកែប្រែ សហព្រះរាជអាជ្ញាបានទទួលស្គាល់ថា សំណើសុំបន្ថែមរបស់ខ្លួន ត្រូវបានចាត់ទុកជាអសារបង់ បន្ទាប់ពីការសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល បញ្ចប់កិច្ចដំណើរការនីតិវិធីប្រឆាំងនឹង នួន ជា[63] ប៉ុន្តែបានស្នើសុំថា គប្បីផ្តល់ឱ្យខ្លួន ៣០០ ទំព័រ និងរយៈពេលប្រាំខែ សម្រាប់ដាក់សារណាតបមួយភាសាសិន ដែលកាលបរិច្ឆេទនៃការដាក់សារណាតបនេះ ត្រូវចាប់ផ្តើមគិតបន្ទាប់ពី ២៥ ថ្ងៃក្រោយពីការជូនដំណឹងអំពីសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ជាភាសាខ្មែរ[64]។ ក្នុងការឆ្លើយតបទៅនឹងសំណើកែប្រែរបស់សហព្រះរាជអាជ្ញា ខៀវ សំផន បានលើកឡើងថា សហព្រះរាជអាជ្ញា គប្បីត្រូវបានបង្គាប់ឱ្យដាក់សារណាតបស្របតាមយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០២/០១ និងដាក់ជាពីរភាសាក្នុងរយៈពេល ១៥ ថ្ងៃគិតចាប់ពីថ្ងៃជូនដំណឹងអំពីសារណាបណ្តឹងសាទុក្ខជាភាសាខ្មែររបស់មេធាវីការពារក្តី។ ខៀវ សំផន នៅតែរក្សាអំណះអំណាងរបស់ខ្លួនដែលបានលើកឡើង ជាការឆ្លើយតបទៅនឹងលើកឡើងពីមុនៗរបស់សហព្រះរាជអាជ្ញា[65]។

25. សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី ពុំបានឆ្លើយតបជាក់លាក់ ប៉ុន្តែបានស្នើសុំជាទូទៅថា អង្គជំនុំជម្រះគប្បីពិចារណាអំពីសិទ្ធិ និងអត្ថប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណីនៅពេលសម្រេចលើអង្គសេចក្តីនៃសំណើរបស់ ខៀវ សំផន[66]។

### *ច្បាប់ជាធរមាន*

26. មាត្រា ៨.៣ នៃសេចក្តីណែនាំអនុវត្តចែងថា សារណាតបទៅនឹងសំណើ ឬសារណា ត្រូវដាក់ក្នុងរយៈពេល ១០ ថ្ងៃប្រតិទិនគិតចាប់ពីការជូនដំណឹងអំពីបណ្តឹងសាទុក្ខចំពោះឯកសារដែលភាគីធ្វើការឆ្លើយ

---

[61] សារណាតបរបស់ ខៀវ សំផន ទៅនឹងសហព្រះរាជអាជ្ញា កថាខណ្ឌ ១៤ ដល់ ២២។

[62] សារណាតបរបស់ ខៀវ សំផន ទៅនឹងសហព្រះរាជអាជ្ញា កថាខណ្ឌ ២៣ (សួរថាតើមូលហេតុអ្វីបានសហព្រះជាអាជ្ញាមិនស្នើសុំពីដំបូងមក)។

[63] សំណើកែប្រែ កថាខណ្ឌ ៧។

[64] សំណើកែប្រែ កថាខណ្ឌ ១១។

[65] សារណាតបទៅនឹងសំណើកែប្រែ កថាខណ្ឌ ១១ និង ១៤។

[66] សារណាតបរបស់សហមេធាវីនាំមុខ ផ្នែកទី ៥។ សារណាតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ផ្នែកទី ៥។

តប។ ដូចបានពិភាក្សាខាងលើ[67] អង្គជំនុំជម្រះ អាចពន្យារពេលសម្រាប់ការដាក់សារណាលើបណ្តឹងសាទុក្ខបាន។

## *ការពិចារណា*

27. អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយ ខៀវ សំផន ថា ទំនាក់ទំនងរបស់បណ្តឹងសាទុក្ខដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញា បានលើកបញ្ហាអង្គច្បាប់ និងអង្គហេតុដែលពុំមែនជាការផ្តោតដោយផ្ទាល់របស់ អ.វ.ត.ក. ឬ យុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌកម្រិតអន្តរជាតិ និងអាស្រ័យហេតុនេះ គឺជាកម្មវត្ថុនៃភាពចាំបាច់ដែលតម្រូវឱ្យមានការដាក់សារណារៀបរាប់ក្បោះក្បាយ។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះពុំជឿជាក់ថា ខៀវ សំផន ត្រូវការពេលវេលាបន្ថែមដើម្បីដោះស្រាយសារណារបស់សហព្រះរាជអាជ្ញាឡើយ។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ខៀវ សំផន បានកំណត់កំហុស ៨៦ នៃអង្គច្បាប់ និង/ឬអង្គហេតុពាក់ព័ន្ធទៅនឹងបទចោទដែលរំពឹងថា ជាមូលដ្ឋាននៃបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា (*ឧ.* ផ្នែក ១៤ នៃសាលក្រម៖ បទបញ្ជារៀបអាពាហ៍ពិពាហ៍)[68]។ កំហុសដែលស្តែងឱ្យឃើញចំនួនប្រាំដែល ខៀវ សំផន បានរកឃើញ គឺពាក់ព័ន្ធទៅនឹង"ផលប៉ះពាល់លើជនរងគ្រោះ"នៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[69] ចំណែកឯកំហុសពីរ គឺពាក់ព័ន្ធទៅនឹង"ការកំណត់ប្រភេទបទល្មើស"ដែលជាប់ពាក់ព័ន្ធទៅនឹងបទបញ្ជារៀបអាពាហ៍ពិពាហ៍[70]។ បន្ថែមលើនេះ កំហុសពីរដែលចោទប្រកាន់នោះ គឺពាក់ព័ន្ធទៅនឹងក្របខណ្ឌច្បាប់ដែលអនុវត្តដោយអង្គជំនុំជម្រះសាលាដំបូង ក្នុងការកំណត់ប្រភេទបទល្មើសនៅក្នុងបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិនៃ"អំពើអមនុស្សធម៌ដទៃទៀតតាមរយៈអំពើដែលបានកំណត់ថា ជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ" និង"ការរំលោភផ្លូវភេទនៅក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ"[71] បទឧក្រិដ្ឋដែលពុំត្រូវបានដោះស្រាយទាល់តែសោះនៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង។

28. លើកលែងតែ ខៀវ សំផន សម្រេចពុំលើកបញ្ហាទាំងនេះនៅក្នុងបណ្តឹងសាទុក្ខរបស់ខ្លួន អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា នឹងមានភាពត្រួតគ្នារវាងការរៀបចំសារណាបណ្តឹងសាទុក្ខរបស់

---

[67] *សូមមើលខាងលើ* កថាខណ្ឌ ១២។

[68] សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៩។

[69] សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៩ (១៤.៨០ ដល់ ១៤.៨៤)។

[70] សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៩ (១៤.៨៥ ដល់ ១៤.៨៦)។

[71] សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៤ (៩.១៥ និង ៩.១៧)។ *សូមមើល*សាលក្រមអង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៧២៨ ដល់ ៧៣២ និង ៧៤០ ដល់ ៧៤៩។

ម្ចាស់បណ្ដឹងសាទុក្ខលើទឡ្ហីករណ៍ពាក់ព័ន្ធទៅនឹងបទបញ្ញានៃការរៀបការ និងការឆ្លើយទៅលើចំណុចដូចគ្នា។ អាស្រ័យហេតុនេះ ពុំមានហេតុផលសមស្របនៅពេលនេះ ក្នុងការពន្យារពេលសារណាតបរបស់ ខៀវ សំផន ទៅនឹងសារណាសហព្រះរាជអាជ្ញារហូតដល់ជាងប្រាំបួនខែនោះឡើយ។ ទោះជាយ៉ាងណាក្ដី អង្គជំនុំជម្រះផ្ដល់រយៈពេល ៣០ ថ្ងៃដល់ ខៀវ សំផន គិតចាប់ពីការជូនដំណឹងអំពីសេចក្ដីសម្រេចនេះ សម្រាប់ដាក់សារណាតបរបស់ខ្លួនទៅនឹងសារណាបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ។

29. អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា លទ្ធភាពរបស់សហព្រះរាជអាជ្ញាក្នុងការប្រមែលប្រមូលធនធានផ្ដោតទៅលើសំណុំរឿង ០០២/០២ នៅពេលពេលវេលាមកដល់ និងថា សារណាចំនួន ៣៥០ ទំព័រ ដែលត្រូវដាក់ក្នុងរយៈពេល ១២០ ថ្ងៃចាប់ពីការជូនដំណឹងអំពីសំណៅបកប្រែសារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន មានលក្ខណៈគ្រប់គ្រាន់សម្រាប់សហព្រះរាជអាជ្ញា ក្នុងការឆ្លើយតបទៅនឹងចំណុចដែលបានលើកឡើងនោះ។

## កិច្ចប្រជុំរៀបចំសវនាការ

*សារណា*

30. ខៀវ សំផន បានស្នើសុំថា “ប្រសិនបើអង្គជំនុំជម្រះតុលាការកំពូលត្រូវពិចារណាផ្ដល់ពេលវេលា និងចំនួនទំព័រតិចជាងអ្វីដែលបានស្នើសុំនោះ អង្គជំនុំជម្រះគប្បីពិចារណាបើកកិច្ចប្រជុំរៀបចំសវនាការជាសាធារណៈ” ដើម្បីធ្វើឱ្យដំណើរការនីតិវិធី“មានលក្ខណៈសមរម្យ និងជាក់ស្ដែង”។ ជាពិសេស គាត់បានស្នើសុំថា អង្គជំនុំជម្រះតុលាការកំពូលអាចអញ្ជើញតំណាងការិយាល័យពាក់ព័ន្ធមកពីការិយាល័យរដ្ឋបាល និងអង្គភាពបកប្រែ នឹងអាចឱ្យអង្គជំនុំជម្រះដឹងបានថា “មេធាវីការពារក្ដីពិតជាជួបឧបសគ្គជាក់ស្ដែងប្រាកដមែន”[72]។

31. សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ពុំបានជំទាស់ទៅនឹងការបើកកិច្ចប្រជុំរៀបចំសវនាការឡើយ[73]។ ប៉ុន្តែ សហព្រះរាជអាជ្ញាលើកឡើងថា ខៀវ សំផន ពុំបានផ្ដល់

---

[72] សំណើរបស់ ខៀវ សំផន កថាខណ្ឌ ៤០។

[73] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២១។ សារណាតបរបស់សហមេធាវីនាំមុខ កថាខណ្ឌ ៩។

យុត្តិកម្មលើសំណើរបស់គាត់នៅក្នុងកាលៈទេសៈបច្ចុប្បន្ននេះ[74]។ ខៀវ សំផន ពុំបានឆ្លើយតបទៅលើបញ្ហានេះទេ។

### *ច្បាប់ជាធរមាន*

32. វិធាន ៧៩(៧) នៃវិធានផ្ទៃក្នុងចែងថា "ដើម្បីសម្របសម្រួលដល់ការប្រព្រឹត្តទៅនៃកិច្ចដំណើរការនីតិវិធីប្រកបដោយយុត្តិធម៌ និងឆាប់រហ័ស អង្គជំនុំជម្រះ[សាលាដំបូង] អាចពិគ្រោះយោបល់ជាមួយភាគីទាំងឡាយ ឬតំណាងរបស់ពួកគេ ក្នុងករណីចាំបាច់ ដោយធ្វើការប្រជុំរៀបចំសវនាការ [...] គោលបំណងនៃកិច្ចប្រជុំនឹងអនុញ្ញាតឱ្យមានការផ្លាស់ប្តូរមតិយោបល់រវាងភាគីទាំងឡាយ ដើម្បី [...] ពិនិត្យឡើងវិញនូវរឿងក្តី ដោយអនុញ្ញាតឱ្យជនជាប់ចោទ លើកឡើងនូវបញ្ហាទាំងឡាយទាក់ទងនឹងរឿងក្តីនោះ"។ អង្គជំនុំជម្រះអាចអញ្ជើញតំណាងការិយាល័យរដ្ឋបាល ព្រមទាំងតំណាងអង្គភាពពាក់ព័ន្ធនានានៃតុលាការចូលរួមប្រជុំ[75]។ វិធាន ១០៤*ស្ទួន* នៃវិធានផ្ទៃក្នុងចែងថា "ប្រសិនបើគ្មានបទប្បញ្ញត្តិដោយឡែកណាមួយនោះទេ រាល់វិធានដែលត្រូវអនុវត្តនៅអង្គជំនុំជម្រះសាលាដំបូង ត្រូវយកមកអនុវត្តចំពោះអង្គជំនុំជម្រះតុលាការកំពូល*ក្នុងករណីសមស្រប*"។

### *ការពិចារណា*

33. អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់ថា ក្នុងពេលបច្ចុប្បន្នតម្រូវឱ្យមានកិច្ចប្រជុំរៀបចំសវនាការនោះឡើយ ។ ដូចបានរៀបរាប់ខាងលើ[76] ឧបសគ្គផ្នែកធនធានដែលបានលើកឡើងរបស់ក្រុមមេធាវីការពារក្តី ខៀវ សំផន[77] ត្រូវបានយកមកពិចារណាយ៉ាងយកចិត្តទុកដាក់ក្នុងការកំណត់លើការបន្ថែមសមស្របណាមួយ។ ដោយពុំមានកាលៈទេសៈដែលប៉ះពាល់ (ឬមានសក្តានុពលប៉ះពាល់) ដល់សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានកិច្ចដំណើរការនីតិវិធីយុត្តិធម៌ ឬមធ្យោបាយការការពារក្តីប្រកបដោយប្រសិទ្ធភាព អង្គជំនុំជម្រះពុំមានសិទ្ធិសម្រេចលើភាពសមស្របនៃធនធាន ដែលបានបែងចែកឱ្យក្រុមមេធាវីការពារក្តីនោះទេ។ បញ្ហានេះស្ថិតនៅក្នុងវិសាលភាពនៃកិច្ចការរដ្ឋបាលរបស់អង្គភាពគាំពារការការពារក្តី ("DSS")

---

[74] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២១។

[75] វិធាន ៧៩(៨) នៃវិធានផ្ទៃក្នុង។

[76] *សូមមើលខាងលើ* កថាខណ្ឌ ២០។

[77] *សូមមើលផងដែរ* សំណើរបស់មេធាវីការពារក្តី ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៩ ឯកសារលេខ F39/1.1 កថាខណ្ឌ ២៨ ដល់ ៣៤។

ដែល តាមវិធាន ១១ នៃវិធានផ្ទៃក្នុង មានសិទ្ធិស្វ័យសម្រេចពាក់ព័ន្ធនឹងបញ្ហានៃមធ្យោបាយការការពារក្តី។ DSS តម្រូវឱ្យអនុម័តតាមបទបញ្ជារដ្ឋបាលពាក់ព័ន្ធទៅនឹងការចាត់តាំងមេធាវីការពារក្តី នឹងត្រូវផ្តល់ជំនួយផ្នែកច្បាប់ជាមូលដ្ឋានដល់ជនក្រីក្រ ដែលតម្រូវឱ្យមានការតំណាងចំពោះមុខ អ.វ.ត.ក.[78]។ អង្គជំនុំជម្រះពិចារណាឃើញថា កិច្ចប្រជុំរៀបចំសវនាការដែលចូលរួមដោយភាគី អ្នកតំណាង និងបុគ្គលិកនៃការិយាល័យរដ្ឋបាល ពុំមែនជាវេទិការសមស្របសម្រាប់ដោះស្រាយបញ្ហាធនធាន និងទំនងជាពុំ"បានជួយសម្រួលដល់ការរៀបចំកិច្ចដំណើរការនីតិវិធីដោយយុត្តិធម៌ និងឆាប់រហ័ស"ដូចការលើកឡើងរបស់ ខៀវ សំផន ឡើយ។

34. បន្ថែមលើនេះ ការអះអាងរបស់ ខៀវ សំផន ដែលថា "ធនធាននៃអង្គភាព[ការបកប្រែផ្ទាល់មាត់និង]បកប្រែ ("ITU") នៅមានកម្រិតតិចជាងខ្លាំងបើធៀបពីមុន" ពុំមានមូលដ្ឋានគាំទ្រគ្រប់គ្រាន់ឡើយ[79]។ ផែនការការងារចុងក្រោយបំផុតរបស់ អ.វ.ត.ក. បានបង្ហាញថា "ការិយាល័យរដ្ឋបាលនៅតែរក្សាផ្តល់សេវាបុគ្គលិកផ្នែកភាសាបន្ថែមដើម្បីជួយគាំទ្រការិយាល័យតុលាការ ក្នុងការធានាបាននូវការបកប្រែទាន់ពេល និងសេវាប្រតិចារិក"[80]។

35. ប្រសិនបើតម្រូវការចាំបាច់ឱ្យមានកិច្ចប្រជុំរៀបចំសវនាការនាពេលអនាគត អង្គជំនុំជម្រះនឹងពិភាក្សាជាមួយភាគី ឬតំណាងរបស់ពួកគេតាមពេលវេលាសមស្រប។

---

[78] វិធាន ១១(១) ១១(២)(ក)(ឆ)(ឈ)។

[79] សំណើរបស់ ខៀវ សំផន កថាខណ្ឌ ១៩។

[80] អង្គជំនុំជម្រះវិសាមញ្ញក្នុងការតុលាការកម្ពុជា"ផែនការការងាររបស់ អ.វ.ត.ក." វិសោធនកម្មលើកទី ២១ ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០១៩ កថាខណ្ឌ ១៧ គេហទំព័ររបស់ អ.វ.ត.ក.៖ https://www.eccc.gov.kh/en/completion-plan-revision-21។

## III. **ផ្នែកសម្រេចសេចក្តី**

36. យោងតាមសំអាងហេតុខាងលើ **អង្គជំនុំជម្រះសម្រេច÷**

**ទទួលយក**ផ្នែកខ្លះនៃសំណើរបស់ ខៀវ សំផន

**បង្គាប់**ថា ខៀវ សំផន ត្រូវដាក់សារណាបណ្តឹងសាទុក្ខរបស់ខ្លួនមិនឱ្យលើសពី **៧៥០** ទំព័រ នៅមុន ឬត្រឹមថ្ងៃទី **២៧** ខែ **កុម្ភៈ** ឆ្នាំ **២០២០** ជាភាសាអង់គ្លេស ឬបារាំង ដែលការបកប្រែជាភាសាខ្មែរ ត្រូវដាក់តាមក្រោយឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន

**បដិសេធ**ផ្នែកដទៃទៀតនៃសំណើរបស់ ខៀវ សំផន

**បង្គាប់**ថា ខៀវ សំផន ត្រូវដាក់សារណាតបទៅនឹងសារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាក្នុងរយៈពេល **៣០** ថ្ងៃគិតចាប់ពីការជូនដំណឹងអំពីសេចក្តីសម្រេចនេះ

**បង្គាប់**ថា សហព្រះរាជអាជ្ញា ត្រូវដាក់សារណាតបទៅនឹងសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន មិនឱ្យលើសពី **៣៥០** ទំព័រ មួយភាសាសិន ក្នុងអំឡុងពេល **១២០** ថ្ងៃចាប់ពីថ្ងៃជូនដំណឹងអំពីសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន និង

**ជូនដំណឹង**ភាគីថា ការឆ្លើយតបណាមួយទៅនឹងសារណាតបនៃបណ្តឹងសាទុក្ខ នឹងត្រូវស្តាប់ទៅតាមកាលបរិច្ឆេទដែលនឹងត្រូវកំណត់ និងជូនដំណឹងក្នុងពេលខាងមុខតាមពេលវេលាសមស្រប។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៩

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រ៊ឹម**